# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

************

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២១០

ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១

សាលដីកា

លេខ : ១៧៣

ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០១

## នាមខាងព្រះមហាក្សត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០១

ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម **ទិត** **មុន្នី** ជាប្រធាន

២- លោក ជីវ កេង ជាចៅក្រមរបាយការណ៍

៣- លោក យស់ សូខឿន ជាចៅក្រម

៤- លោក ឈឹម ស៊ីផល ជាចៅក្រម

៥- លោក គង់ ភីរុណ ជាចៅក្រម

ក្រឡាបញ្ជី

លោក សុង ម៉ៅ

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកា លេខ ៩៤ " ឈ " ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១ នៃ សំណុំរឿងរដ្ឋប្បវេណី លេខ ១៥០ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ។

- រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះលឹម ហួរឡេង ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ មុខរបរ ទីលំនៅ ផ្ទះលេខ ៦៦$E_2$ ផ្លូវ ០៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ អ៊ន់ " ស " ម្តាយឈ្មោះ ហ៊ន់ " ស " ប្រពន្ធឈ្មោះ ស៊ុន វួចលៀង ។

មានមេធាវី លោក ទូត លុច

- និងចុងបណ្តឹងសាទុក្ខឈ្មោះ សុខ ទី ភេទប្រុស អាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរ ពាណិជ្ជករ ទីលំនៅផ្ទះ ៣០$E_0$ ផ្លូវ ១១០ សង្កាត់ផ្សារកណ្តាលទី ១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ អ៊ុំង សុខ " ស " ម្តាយឈ្មោះ អ៊ីវ ឆេង " ស " ប្រពន្ធឈ្មោះ មុយ ណៃ ។

មានមេធាវី លោក ការ សាវុត្ថ

- អំពីវិវាទ : ប្តឹងទាមទារដី

បានឃើញបណ្តឹងសាទុក្ខលេខ ២៣៩ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១ របស់ លោក លឹម ហួរឡេង ប្តឹងមិនសុខចិត្ត ពីសាលដីកា រដ្ឋប្បវេណី លេខ ៩៤ " ឈ " ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ

២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ២១០ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០០ របស់លោក សុខ ទី ប្តឹងទាមទារដីពីឈ្មោះ លឹម ហួរទៀង និង ប្រពន្ធឈ្មោះ ស៊ុន វួចលៀង ដោយសំអាងហេតុថា កាលពីឆ្នាំ ១៩៩២ ឈ្មោះ លឹម ហួ ហៀង បានឱ្យខ្លួនទិញដីមួយកន្លែង ដែលមានទំហំ ២១,៩៨ ម៉ែត្រការេ ហើយដីនេះ គឺបានទិញពីឈ្មោះ ថៃ ប៊ុនរ៉ុង ក្នុងតំលៃ ៧៥០០០០$ ដោយមានធ្វើកិច្ចសន្យា ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩២ ហើយចាប់ពីទិញមក ឈ្មោះ លឹម ហួ ហៀង បានឱ្យខ្លួនកាន់កាប់គ្រប់គ្រង ថែរក្សាដោយខ្លួនបានបើកភោជនីយដ្ឋាន នៅលើដីនោះ តាំងពីឆ្នាំ ១៩៩៧ រហូតដល់សព្វថ្ងៃស្រាប់ តែមកដល់ឆ្នាំ ២០០០នោះ ឈ្មោះ លឹម ហួរទៀង និង ប្រពន្ធបានលួចធ្វើប័ណ្ណកម្មសិទ្ធិលេខ ភព.០១៩៣៥ យកតែម្តង ហើយបានធ្វើការប្រកាសលក់ដីនេះ ។

បានឃើញ ដីកាសំរេចកិច្ចការប្រញាប់លេខ១៥ប្រ " ជ " ចុះថ្ងៃទី១៥ខែវិច្ឆិកា ឆ្នាំ ២០០០ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងសុំដីកាសំរេចកិច្ចការប្រញាប់ ចុះថ្ងៃទី ០២-១១-២០០០ របស់ឈ្មោះ សុខ ទី ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ៣០-១០-២០០០ របស់ឈ្មោះ លឹម ហួ ហៀង ឱ្យទៅឈ្មោះ សុខ ទី ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១៤-១១-២០០០ របស់ឈ្មោះ លឹម ហួរទៀង ឱ្យទៅឈ្មោះ គង់ ចំរើន ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤- ហាមឃាត់ឈ្មោះ លឹម ហួរទៀង និង ប្រពន្ធឈ្មោះ ស៊ុន វួចលាង មិនឱ្យលក់-ដូរ, ជួល, បញ្ចាំ, ផ្ទេរសិទ្ធិ ធ្វើអំណោយឱ្យអ្នកដទៃ នូវដីឡូត៍លេខ ៨៤ ផ្លូវលេខ ៦៣ កែង ១៩៤ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព.០១៩៣៥ ចុះថ្ងៃទី ០២-៣-២០០០ ជាបណ្តោះអាសន្នរង់ចាំតុលាការសំរេចអង្គសេចក្តី ។

៥- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៤.០០០រៀល ពីដើមចោទឈ្មោះ សុខ ទី ដែលបានបង់ទុកមុនរួចជាស្រេច ។

៦- ដីកាសំរេចនេះ មានអនុភាពយកទៅអនុវត្តភ្លាមៗ ទោះជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ០២ " ជ " ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ របស់តុលាការក្រុងភ្នំពេញ សំរេចចំពោះមុខដើមចោទ និង តំណាងចុងចម្លើយ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ០១-១១-២០០០ របស់ដើមចោទឈ្មោះ សុខ ទី ទុកជា

ត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ៣០-១០-២០០០ របស់ឈ្មោះ លឹម ហួហៀង ឱ្យមកឈ្មោះ សុខ នី ត្រឹមត្រូវតាមច្បាប់ ។

៣- ទទួលស្គាល់លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី ១៥-១១-២០០០ របស់ ឈ្មោះ លឹម ហួរទៀង មកឈ្មោះ គង់ ចំរើន ត្រឹមត្រូវតាមច្បាប់ ។

៤- បដិសេធប័ណ្ណសំគាល់សិទ្ធិកាន់កាប់ អចលនវត្ថុលេខ ភព.០១៩៣៥ ចុះថ្ងៃទី ០២-០៣-២០០០ របស់មន្ទីរសុរិយោដី រាជធានីភ្នំពេញ ចោលជាអសារបង់ ។

៥- ប្រគល់ដីឡូត៍លេខ ៨៤ ផ្លូវលេខ ៦៣ កែង ១៩៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ មានព្រំប្រទល់ខាងជើង ទល់នឹងផ្លូវលេខ ១៩៤ ខាងត្បូងទល់នឹងដីឡូត៍លេខ ៧០ ( មន្ទីរពេទ្យ ) ខាងកើតទល់ដីឡូត៍លេខ ៨២ ( មន្ទីរនគរបាលរាជធានី ) ខាងលិចទល់នឹងផ្លូវលេខ ៦៣ ឱ្យទៅឈ្មោះ លឹម ហួហៀង និងឈ្មោះសុខ នី ( ជាតំណាងក្រុមហ៊ុនមៀង លីហេង ) ចាប់ពីថ្ងៃសាលក្រមស្ថាពរតទៅ ។

៦- បង្គាប់ឱ្យមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដី ធ្វើប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ នៃ ដីឡូត៍លេខ ៨៤ ផ្លូវលេខ ៦៣ កែង ១៩៤ សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ខាងលើ ឱ្យឈ្មោះ លឹម ហួហៀង និង ឈ្មោះ សុខ នី ទៅតាមច្បាប់ចាប់ពីសាលក្រមស្ថាពរ ។

៧- បង្គាប់ឱ្យចុងចម្លើយឈ្មោះ លឹម ហួរទៀង បង់ប្រាក់ប្រដាប់ក្តីចំនួន ៧០០០រៀល ប្រាក់នេះ ត្រូវបានកាត់យកពីប្រាក់ចំនួន ៧.០០០រៀល ដែលដើមចោទបានបង់ទុកជាមុនស្រេច ។

និង ឱ្យឈ្មោះ លឹម ហួរទៀង បង់ពន្ធសមាមាត្រចំនួនមួយភាគរយ គិតពីតំលៃដី ៧៥០០០០ ដុល្លាអាមេរិក ( ចិតសិបប្រាំម៉ឺនដុល្លាអាមេរិក ) ។ ប្រាក់ ១ ភាគរយនេះ ត្រូវបង់ចូលថវិការដ្ឋ ចំនួន ៨០% និង រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ពេលសាលក្រមចូលជាស្ថាពរ ។

៨- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ និង តំណាងចុងចម្លើយ បើភាគីណាមិនសុខចិត្ត និង សាលក្រមនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល ០២ ខែ ចាប់ពីថ្ងៃប្រកាសសាលក្រម ។

បានឃើញ បណ្តឹងឧទ្ធរណ៍ លេខ ០១ " ជ " ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០១ របស់លោក គង់ ចំរើន ប្តឹងមិនសុខចិត្ត និង សាលក្រមលេខ ០២ " ជ " ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ លើសាលក្រមទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ៩៤ " ឈ " ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខមេធាវីតំណាងឱ្យដើមចោទ និង មេធាវីការពារឱ្យដើមបណ្តឹងឧទ្ធរណ៍ កំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១០-០១-២០០១ របស់ឈ្មោះ គង់ ចំរើន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់ និង គតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០២ " ជ " ចុះថ្ងៃទី ១០-០១-២០០១ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣- កាត់យកប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០-រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល និង អាជ្ញាធរតុលាការ ៥០០០រៀល ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមេធាវីតំណាងឱ្យដើមចោទ និង មេធាវីការពារឱ្យដើមបណ្តឹងឧទ្ធរណ៍ កំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ ២៣៩ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១ របស់លោក លឹម ហួរទៀង ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណី លេខ ៩៤ "ឈ" ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើគ្រង់ចំណុច នៃ សេចក្តីសំរេចទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី ១០-៩-២០០១ របស់លោក លឹម ហួរទៀង

បានឃើញ សារណាតប ចុះថ្ងៃទី ១២-៩-២០០១ របស់លោក សុខ ទី

បានស្តាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា : ចំពោះរឿងនេះ សាលាឧទ្ធរណ៍បានសំរេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេច ចុះ ។

ក្រឡាបញ្ជីអានសារណារបស់ លឹម ហួរទៀង

បានស្តាប់ចម្លើយរបស់ឈ្មោះ សុខ ទី ឆ្លើយថា : ចំពោះរឿងនេះ ខ្លួនបានប្រគល់សិទ្ធិឱ្យមេធាវីចាត់ចែងហើយ ពេលនេះខ្លួនគ្មានអ្វីបន្ថែមទៀតទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះលឹម ហួរហៀង ឆ្លើយថា : ខ្លួនឈ្មោះ លឹម ហួរហៀង អាយុ ៤៧ឆ្នាំ មុខរបរ ធ្វើរោងចក្រដំរ កែច្នៃ ផ្ទះស្នាក់នៅស្នាក់ការក្រុមហ៊ុន ។ រឿងនេះ ខ្លួនបានប្រគល់សិទ្ធិ ឱ្យឈ្មោះ សុខ ទី តវ៉ាក្តីមែន ខ្លួនបានសហការជាមួយក្រុមហ៊ុន មៀង លីហេង ទិញដីនេះ ខ្លួនមានចំណែកហ៊ុន ៦០% កាលពីខ្លួនទិញដីពី ថៃ ប៊ុនរ៉ុង ខ្លួនបានប្រគល់សិទ្ធិឱ្យក្រុមហ៊ុនចាត់ចែង ហើយបានកាន់កាប់ដីនេះពីឆ្នាំ ១៩៩២ ។

លោក ទូត លុច ជាមេធាវីការពារឱ្យ លឹម ហួរទៀង បានធ្វើសេចក្តីសន្និដ្ឋានថា :

ដោយសារមានវត្តមានរបស់ជនម្នាក់ក្នុងពេលសវនាការនេះ ធ្វើឱ្យអង្គសវនាការទាំងមូលក៏ដូចរូបខ្ញុំមានការភ្ញាក់ផ្អើល មិនទាន់មានឯកសារណាមួយបញ្ជាក់ថា អ្នកដែលចូលរួមនេះជា លឹម ហួរហៀង ឡើយ ដូចនេះខ្ញុំ យល់ថា ចាំបាច់ត្រូវធ្វើការអង្កេតបន្ថែម ។ ក្នុងសេចក្តីសំរេចរបស់ក្រុង ដាក់ថា លឹម ហួរទៀង ហើយប័ណ្ណកម្មសិទ្ធិធ្វើក្រោយ ជាការត្រឹមត្រូវតាមការណែនាំរបស់រដ្ឋាភិបាល ។ សុខ ទី បានប្តឹងថា ដីនេះជារបស់ខ្លួន តែពុំមានឯកសារអ្វីទាំងអស់ តាមឯកសារដែលខ្ញុំបានពិនិត្យ និង តាមសេចក្តីសំរេចរបស់សាលា...

ក្រុងបញ្ជាក់ថា ដីនេះ ជាកម្មសិទ្ធិរបស់ លឹម ហួរឡេង ។ ការអង្កេត និង ការវាស់វែងដីនេះ ធ្វើឡើងមានលក្ខណៈត្រឹមការចេញប្លង់កម្មសិទ្ធិក៏ធ្វើរួចហើយដែរ ដើមឡើយដីនេះ លឹម ហួរហៀង ទិញហើយប្រគល់ឱ្យ លឹម ហួរឡេង ធ្វើកម្មសិទ្ធិដីនេះ ពុំមានភស្តុតាងបញ្ជាក់ថា ជារបស់ឈ្មោះ សុខ ទី ទេ ។ ក្នុងពាក្យបណ្តឹងរបស់ សុខ ទី ថា ដីនេះ លឹម ហួរឡេង ឱ្យលុយទិញ ក្រោយមកបែរជា ថាដីនេះ ជារបស់ខ្លួនទៅវិញ។ សុខ ទី បានក្លែងលិខិតមួយថា មានការផ្ទេរសិទ្ធិឱ្យខ្លួន តាមពិតគ្មានទេ សុខ ទី ថា លឹម ហួរឡេង សញ្ជាតិកម្ពុជាទេ តែ លឹម ហួហៀង ចូលឆ្លើយ ពេលនេះ តុលាការឃើញផ្ទាល់ភ្នែកស្រាប់ហើយ គឺ មិនមែនសញ្ជាតិកម្ពុជាទេ គឺ ជាជនជាតិ តៃវ៉ាន់ សុទ្ធសាធ ហើយអាយុទៀតក៏ខុសគ្នា ។ ក្រសួងពាណិជ្ជកម្មបានបញ្ជាក់ហើយថា ក្រុមហ៊ុន មៀង លីហេង បានទទួលការអនុញ្ញាតិធ្វើអាជីវកម្មនៅឆ្នាំ១៩៩៦ ប៉ុណ្ណោះ ឯក្បាលលិខិតដាក់ថា ក្រុមហ៊ុននេះដំណើរការឆ្នាំ១៩៩២នេះ បង្ហាញឱ្យឃើញថា សុខ ទី បានក្លែងលិខិតយ៉ាងពិតប្រាកដ ដើម្បីបានដីទំនាស់នេះ ។ សរុបទៅឃើញថា លិខិតដែលឈ្មោះ សុខ ទី បានដាក់ជូនមកតុលាការកំពូលនេះ គឺសុទ្ធតែក្លែងក្លាយទាំងអស់ ។ សូមពិចារណាថា ហេតុអ្វីក្រុងធ្វើការកែប្រែលិខិតកាន់កាប់ដីពី លឹម ហួរឡេង ទៅ លឹម ហួរហៀង វិញ តាមរយៈលោក ថេង ប៊ុនម៉ា នោះ ? តើមានប្រយោជន៍អ្វីចាំបាច់លោក ថេង ប៊ុនម៉ា សុំធ្វើការកែប្រែនោះ នេះពិតជាមានការសមគំនិតគ្នា ដើម្បីរំលោភយកដីទំនាស់ ។ ក្នុងសាលក្រម និង សាលដីការបស់សាលាឧទ្ធរណ៍ មានពីរចំណុចធំៗ ដែលជាកំហុសឆ្គងធ្ងន់ធ្ងរគឺ :

១- លិខិតប្រគល់សិទ្ធិឱ្យ សុខ ទី ធ្វើឡើងដោយមិនបានត្រឹមត្រូវ ព្រោះគ្មានការបញ្ជាក់ពីអង្គការមានសមត្ថកិច្ច តាមត្រឹមត្រូវរាល់ការផ្ទេរសិទ្ធិអ្វីមួយទៅឱ្យនរណាម្នាក់ចាំបាច់ត្រូវមានការបញ្ជាក់ បើគ្មានការបញ្ជាក់ត្រូវទុកជាមោឃៈ ព្រោះបើធ្វើយ៉ាងនេះ បាននរណាក៏អាចធ្វើលិខិតបានដែរ ដោយគ្រាន់តែផ្តិតមេដៃមិនដឹងនរណាផង ។

២- លឹម ហួរហៀង ជាជនបរទេស តើហេតុអ្វីតុលាការកម្ពុជា ត្រូវប្រគល់ដីឱ្យជនបរទេសធ្វើកម្មសិទ្ធិ វាពិតជាខុសពីរដ្ឋធម្មនុញ្ញ ខុសពីច្បាប់ភូមិបាល ។ ខ្ញុំយល់ថា រាល់ការផ្ទេរសិទ្ធិ និង ប្រគល់សិទ្ធិរបស់ សុខ ទី គ្មានសុពលភាពតាមផ្លូវច្បាប់ទេ លឹម ហួរឡេង ពិតជាម្ចាស់កម្មសិទ្ធិលើដីនេះ ។ ខ្ញុំសូមឱ្យតុលាការកំពូល សំរេចបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោល និង សាលក្រមតុលាការក្រុងភ្នំពេញ ហើយបង្វិលឱ្យសាលាឧទ្ធរណ៍សំរេចសេចក្តីឡើងវិញ ។

លោក ការ សាវុត្ថ មេធាវីការពារឱ្យឈ្មោះ សុខ ទី បានធ្វើសេចក្តីសន្និដ្ឋានថា : ជាដំបូងនេះ ខ្ញុំសូមឆ្លើយតប និង ការលើកឡើង របស់មេធាវី ទូត លុច សូមបញ្ជាក់ថា ឈ្មោះលឹម ហួរហៀង នេះ នៅមុខតុលាការស្រាប់ហើយ គាត់ជាជនជាតិ ខ្មែរ យ៉ាងពិតប្រាកដ ធ្លាប់រស់នៅស្រុកខ្មែរ និង មានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវទៀតផង ។ ក្រុមហ៊ុនបានសុំច្បាប់វិនិយោគទុន តាំងពីឆ្នាំ ១៩៩២ មកម្ល៉េះ តែពេលនោះរដ្ឋាភិបាលមិនទាន់អនុញ្ញាតិឱ្យភ្លាមៗទេ គេថា ការអង្កេតដី កូនក្តី ខ្ញុំមិនធ្វើការតវ៉ា ឱ្យតវ៉ាយ៉ាងម្តេច បើអ្នកចុះមកអង្កេតវាស់ដីពេលនោះថា ចុះវាស់វែង និង អង្កេតដីឱ្យ លឹម ហួហៀង ដដែលនោះ ។ ខ្ញុំមានភស្តុតាងថា កូនក្តីខ្ញុំបានចូលហ៊ុនគ្នាទិញដីនេះមែន ឯការថា អាយុខុសគ្នា ដោយកូនក្តីខ្ញុំ គាត់ឆ្លើយខ្លាចខុស

ពីមុន ឆ្លើយតាមគាត់ចាំថា អាយុ ៤៧ឆ្នាំ ទៅ ។ អ្នកឧកញ្ញា ថេង ប៊ុនម៉ា ជាអ្នកលក់ដីនេះ ដូច្នេះគាត់ជាអ្នកចេញមុខការពារឱ្យអ្នកទិញហើយ នេះជាការត្រឹមត្រូវតាមច្បាប់ ។ ការទិញលក់ដីមានកិច្ចសន្យាត្រឹមត្រូវ អ្នកលក់គឺឧកញ្ញា ថេង ប៊ុនម៉ា អ្នកទិញគឺ សុខ នី មានប័ណ្ណប្រថាប់ត្រាត្រឹមត្រូវផង ហើយឯកសារបញ្ជាក់ថា សុទ្ធតែដាក់ឈ្មោះ លឹម ហួរហៀង ទាំងអស់ តែពេលធ្វើសំណើសុំប្តូរបែរជាក្រុងសំរេចច្រឡំឈ្មោះ ដាក់ថា លឹម ហួរទៀង ទៅវិញ ។ ក្រោយមកឧកញ្ញា ថេង ប៊ុនម៉ា បានបញ្ជាក់ថា គាត់បានលក់ដី ឱ្យ សុខ នី តាមរយៈតុលាការនេះ ខ្ញុំសូមសួរលោកមេធាវីរបស់ លឹម ហួរទៀង ថា តើដីនេះ លឹម ហួរទៀង បានពីណាមក បានពីប្រភពណា ? សូមរកប្រភពដើមដីទំនាស់នេះ មកពីណា ដើមបណ្តឹងសាទុក្ខពុំមានឯកសារបញ្ជាក់ថា ទិញដីទំនាស់នេះពីណាឡើយ ឯឈ្មោះ សុខ នី មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដីនេះទិញត្រឹមត្រូវតាមច្បាប់ ព្រមទាំងមានអ្នកលក់បញ្ជាក់ស្រាប់ ។ សូមតុលាការកំពូល ដកលំសាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

មេធាវី លោក ទូត លុច បានសន្និដ្ឋានបន្ថែមទៀតថា : លោក កា សាវុត្ថ នៅតែទទួលស្គាល់ថា អ្នកចូលមកឆ្លើយនេះ ជា លឹម ហួរហៀង ចំណែកខ្ញុំមិនជឿឡើយ បើឈ្មោះនេះ ជា លឹម-ហួរហៀង មែន មិនចាំបាច់មកប្តឹងផ្តល់ទេ គ្រាន់តែទៅជួបឈ្មោះលឹម ហួហៀង ទៅបានដីមកវិញទៅហើយ ដូចនេះ មានតែស្ពានទូតចិនប៉ុណ្ណោះ ទើបអាចបញ្ជាក់ពីអត្តសញ្ញាណរបស់ លឹម ហួរហៀង ពេលនេះ មែនរឺ មិនមែន ។ ការលើកឡើងថា អ្នកចូលមកឆ្លើយនេះ ជា លឹម ហួរហៀង ហើយជាខ្មែរនោះ សូមបញ្ជាក់ពីសញ្ជាតិតាមច្បាប់របស់ខ្មែរយើង ជនបរទេសអាចចូលសញ្ជាតិបានត្រូវគោរពលក្ខខ័ណ្ឌណាខ្លះ ? ដូចនេះការអះអាងរបស់មេធាវីដើមចោទនេះដូចជាងាយពេក ។ ខ្ញុំបានជួបកូនក្តីខ្ញុំបញ្ជាក់ថា ដីទំនាស់នេះគឺលឹម ហួរហៀង ជាអ្នកទិញ ពីឧកញ្ញា ថេង ប៊ុនម៉ា ក្រោយមកបានប្រគល់ឱ្យកូនក្តីខ្ញុំ ( លឹម ហួរទៀង ) ធ្វើជាកម្មសិទ្ធិតាមច្បាប់ដោយមានការទុកចិត្តហើយ កូនក្តីខ្ញុំបានកាន់កាប់ដីនេះរហូតដោយឱ្យ សុខ នី ធ្វើអាជីវកម្មលក់ស៊ុប តែកូនក្តីខ្ញុំក៏បានប្រយោជន៍ដែរ ។ លឹម ហួរហៀង មែនទែន បានប្រគល់ដីនេះ ឱ្យកូនក្តីខ្ញុំ ធ្វើជាកម្មសិទ្ធិ ដោយសារគាត់ ជាជនបរទេស ហើយដីនេះឈ្មោះ លឹម ហួរហៀង ជាអ្នកចេញលុយទិញទាំងអស់ ទើបប្រគល់ដីឱ្យកូនក្តីខ្ញុំគ្រប់គ្រង ។

មេធាវី លោក ការ សាវុត្ថ បានសន្និដ្ឋានបន្ថែមទៀតថា : កាលដែលនៅតុលាការថ្នាក់ក្រោមកូនក្តីខ្ញុំ មិនចូលនោះ ជាសិទ្ធិរបស់គាត់ ដោយគាត់មានមេធាវីហើយ ហើយក៏បានប្រគល់សិទ្ធិឱ្យសុខ នី រួចហើយដែរ ។ អ្នករត់ការធ្វើប័ណ្ណកម្មសិទ្ធិ ក្រោយមកទើបដឹងថា ប័ណ្ណនេះខុស ទើបបានជាសុំឱ្យកែប្រែឈ្មោះប័ណ្ណកម្មសិទ្ធិនោះ ។

មេធាវី លោក ទូត លុច បានសន្និដ្ឋានបន្ថែមទៀតថា : អំពីបញ្ហាប័ណ្ណកម្មសិទ្ធិកូនក្តីខ្ញុំបានធ្វើត្រឹមត្រូវទាំងអស់ ក្រោយមកបែរជាគេបញ្ឆោតយកប័ណ្ណទៅទុក ធ្វើឱ្យកូនក្តីខ្ញុំចុះការសែតប្តឹង រកប័ណ្ណកម្មសិទ្ធិដីនេះវិញ ។ តាមនីតិវិធី ការធ្វើប័ណ្ណកម្មសិទ្ធិមន្ត្រីមានសមត្ថកិច្ច ធ្វើតាមការស្នើសុំរបស់កូនក្តីខ្ញុំ ៕

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់លោក លឹម ហួរទ្បេង , ចម្លើយរបស់លោក សុខ នី និង លោក លឹម ហួរហៀង និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវី នៃ គូភាគី .
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៣៩ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១ របស់លោក លឹម ហួរទ្បេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះបាន តាម មាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលលោក លឹម ហួរទ្បេង លើកឡើងក្នុងសារណា ចុះថ្ងៃទី ១០-៩-២០០១ របស់លោក ថា ដីទំនាស់នេះ ជាដីរបស់លោក ដោយលោកមានសេចក្តីសំរេចលេខ ១៧២៧ ចុះថ្ងៃទី ១២-១២-៩២ របស់អាជ្ញាធរក្រុងភ្នំពេញ មានកំណត់ហេតុអង្កេតវាស់វែងដី ចុះថ្ងៃទី ១៤-០១-២០០០ និង មានប័ណ្ណកម្មសិទ្ធិដីលេខ ភព ០១៩៣៥ ចុះថ្ងៃទី ០២-៣-២០០០ បញ្ជាក់ថា ជាដីរបស់លោកនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា កំណត់ហេតុអង្កេតវាស់វែងដី និង ប័ណ្ណកម្មសិទ្ធិដី កើតចេញមកពីសេចក្តីសំរេចលេខ ១៧២៧ ចុះថ្ងៃទី ១២-១២-៩២ របស់អាជ្ញាធរក្រុងភ្នំពេញ ហើយសេចក្តីសំរេចនេះ កើតចេញពីលិខិតផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ថៃ ប៊ុនរ៉ុង នូវដីទំនាស់ទៅឱ្យឈ្មោះ សុខ នី និង លឹម ហួរហៀង កើតពីលិខិតរបស់ស្នងការដ្ឋាននគរបាលក្រុងភ្នំពេញ និង ពីលិខិតបង្កាន់ដៃប្រថាប់ត្រារបស់លោក លឹម ហួរហៀង ទាំងអស់ គ្រាន់តែមានការភ័ន្តច្រឡំអក្ខរាវិរុទ្ធលើសេចក្តីសំរេចត្រង់អក្សរ " ហៀង " ទៅជា អក្សរ " ទ្បេង " ប៉ុណ្ណោះ ប៉ុន្តែសេចក្តីសំរេចនេះ ក៏ត្រូវបានអាជ្ញាធរក្រុងភ្នំពេញ សំរេចកែប្រែអក្សរ " ទ្បេង " ទៅជាអក្សរ " ហៀង " វិញ តាមលិខិតលេខ ៥៥៥ឆត. ចុះថ្ងៃ ២៦-៣-២០០១ រួចហើយ ។ ដូច្នេះចុងចម្លើយពុំអាចយកសេចក្តីសំរេចលេខ ១៧២៧ លស. ចុះថ្ងៃទី ១២-១២-៩២ , កំណត់ហេតុអង្កេតដី ចុះថ្ងៃទី ២៤-០១-២០០០ និង ប័ណ្ណសំគាល់សិទ្ធិលេខ ភព ០១៩៣៥ ចុះថ្ងៃទី ០២-៣-២០០០ របស់អាជ្ញាធរក្រុងភ្នំពេញ មកធ្វើជាភស្តុតាង ដើម្បីទាមទារយកដីទំនាស់នេះ បានឡើយ ។

- យល់ឃើញថា ការដែលលោក លឹម ហួរទ្បេង លើកឡើងក្នុងសារណារបស់លោកទៀតថា ឈ្មោះ លឹម ហួរហៀង ដែលជាអ្នកប្រគល់សិទ្ធិឱ្យលោក សុខ នី គ្មានរូបរាង អត្តសញ្ញាណសំគាល់ពិតប្រាកដ និង មិនដឹងជាស្នាមមេដៃអ្នកណា ហើយកិច្ចព្រមព្រៀង ចុះថ្ងៃទី ១១-១១-៩២ ដែលបានដាក់ឈ្មោះថា ក្រុមហ៊ុន មៀង លីហេង វិនិយោគ ជាកិច្ចព្រមព្រៀងពុំត្រឹមត្រូវ ដែលលោក សុខ នី ពុំអាចធ្វើជា ម្ចាស់លើដីទំនាស់បាននោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះ លោក លឹម ហួរហៀង បានចូលមកឆ្លើយបំភ្លឺនៅពេលសវនាការកំពូល ដោយផ្ទាល់ក្នុងនាមជាដើមចោទ ដោយមានលិខិតឆ្លងដែន និង អត្តសញ្ញាណប័ណ្ណ

សំគាល់ផង ហើយលោកក៏បានទទួលស្គាល់ថា លោក ពិតជាបានព្រមព្រៀងទិញដីជាមួយលោក សុខ ទី និង បានផ្ទេរសិទ្ធិឱ្យលោកសុខ ទី កាន់កាប់ប្រាកដមែន ដូច្នេះលោកលឹម ហួរទ្បេង ពុំមានភស្តុតាង អាចបដិសេធ មិនទទួលស្គាល់សិទ្ធិរបស់ដើមចោទលើដីទំនាស់នេះ បានឡើយ ។

- យល់ឃើញថា មានភស្តុតាង គ្រប់គ្រាន់បញ្ជាក់ថា ឈ្មោះលឹម ហួរទៀង ជាចុងចម្លើយ ពុំមានអត្តសញ្ញាណត្រឹមត្រូវពិតប្រាកដទេ ហើយក៏គ្មានភស្តុតាងណាមួយបញ្ជាក់ថា ឈ្មោះ ថេង ប៊ុនម៉ា ប្រធានក្រុមហ៊ុនថៃ ប៊ុនរ៉ុង បានលក់ដីទំនាស់ឱ្យឈ្មោះ លឹម ហួរទៀង ដែរ ថែមទាំងគ្មានភស្តុតាងអ្វី ដើម្បី បញ្ជាក់ថា បានដីនេះ មកពីណា ប្រសិនបើលោកពុំបានទិញពីក្រុមហ៊ុន ថៃ ប៊ុនរ៉ុង ទេនោះ ។ ដូច្នេះលោក ពុំអាចមានសិទ្ធិលើដីទំនាស់នេះបានឡើយ ។

- យល់ឃើញថា នៅពេលសវនាការនេះ លោកមេធាវីចុងចម្លើយ បានលើកឡើងថា ដី ទំនាស់នេះ លោក លឹម ហួរហៀង បានទិញពីក្រុមហ៊ុន ថៃ ប៊ុនរ៉ុង តែម្នាក់ឯងទេ ហើយដោយមានការ ទុកចិត្តលើឈ្មោះ លឹម ហួរទៀង ទើបប្រគល់ឱ្យ លឹម ហួរទៀង កាន់កាប់ ។ ការលើកឡើងបែបនេះ ពុំ មានភស្តុតាងណាបញ្ជាក់ថា លោក លឹម ហួរហៀង បានប្រគល់សិទ្ធិ ឱ្យលោក លឹម ហួរទៀង កាន់កាប់ ទេ ហើយនៅពេលសវនាការនេះ លោក លឹម ហួរហៀង បញ្ជាក់ថា លោកបានប្រគល់ដីទំនាស់ឱ្យលោក សុខ ទី កាន់កាប់ទេ ។ ម្យ៉ាងទៀតការអះអាងរបស់មេធាវី ផ្ទុយពីចម្លើយលោក លឹម ហួរទៀង នៅ មុខចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ដែលថា ដីទំនាស់នេះ លោក ជាអ្នកចេញលុយឱ្យលោក សុខ ទី ទិញពី ថៃ ប៊ុនរ៉ុង ។

- យល់ឃើញថា ការដែលមេធាវី ចុងចម្លើយលើកឡើងថា ជនឈ្មោះ លឹម ហួរហៀង ដែលឈរមុខតុលាការ ជាសញ្ជាតិ ថៃវ៉ាន់ ដែលតុលាការពុំទាន់បានស៊ើបអង្កេត ពីអត្តសញ្ញាណនៅឡើយ ហើយក្នុងពាក្យបណ្តឹង និង ក្នុងកិច្ចព្រមព្រៀងដាក់ថា លោក លឹម ហួរហៀង ជាសញ្ជាតិខ្មែរ ដោយលោក សុខ ទី បានក្លែងបន្លំយកឈ្មោះ លឹម ហួរហៀង មកយកដីនេះនោះ តុលាការកំពូលពុំអាចពិចារណាបាន ទេ ពីព្រោះលោក លឹម ហួរហៀង ជាភាគីដើមចោទជាអ្នកទិញដីទំនាស់ជាមួយលោក សុខ ទី ពុំអាចត្រូវ បាត់បង់ដីនេះ ដោយសារតែបញ្ហាសញ្ជាតិទេ ហើយពិនិត្យលើលិខិតឆ្លងដែន និង អត្តសញ្ញាណប័ណ្ណ ឃើញ ថា រូបថតនៅលើលិខិតឆ្លងដែរ និង លើអត្តសញ្ញាណប័ណ្ណដូចគ្នានឹងសាម៉ីខ្លួន ដែលបញ្ជាក់ថា លោកឈ្មោះ លឹម ហួរហៀង ដែលឈរនៅមុខតុលាការពេលនេះដែរ ។

- យល់ឃើញថា លោក លឹម ហួរទៀង បានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមក តុលាការកំពូល រួចហើយ ប៉ុន្តែលោក ពុំបានមកចូលរួមនាសវនាការនេះទេមានតែមេធាវីរបស់លោកមកចូល រួមដូច្នេះ តុលាការកំពូល ជំនុំជំរះ កំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៩៤ " ឈ " ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទម្រង់ និងគតិ ច្បាប់ហើយ ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខលោក សុខ ទី និងលោក លឹម ហួរទៀង
### កំបាំងមុខលោក លឹម ហួរទៀង ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ ២៣៩ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១ របស់លោក លឹម ហួរទៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹង គតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៩៤ " ឈ " ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៩០០០រៀល ដែលលោក សុខ ទី បានបង់ជូសនៅតុលាការកំពូលរួចហើយ គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន ៤០០០ រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន ៨០០ រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,
- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យលោក លឹម ហួរទៀង សងប្រាក់ ១៩.០០០ រៀល នេះ ទៅលោក សុខ ទី វិញ ។

បង្គាប់ឱ្យលោក លឹម ហួរទៀង បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការក្រុងភ្នំពេញ ។

៤- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០១ ។